សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការជិះម៉ូតូឌុប។
អញ្ចឹងជាទូទៅមធ្យោបាយធ្វើដំណើរគឺមានច្រើន នៅក្នុងប្រទេសកម្ពុជាយើង
ដោយសារតែប្រទេសកម្ពុជាគឺជាប្រទេសមួយ ដែលកំពុងតែអភិវឌ្ឍ អញ្ចឹងមធ្យោបាយធ្វើដំណើរ
គឺពេលខ្លះប្រជាជន គឺអត់មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួននោះទេ
ដូចថា[...]គាត់ចង់ទៅណាមកណា អញ្ចឹងគាត់ជិះឡាន ឬក៏ជិះតាក់ស៊ី ជិះឡានក្រុង
ឬក៏ជិះម៉ូតូឌុបជាដើម។ អញ្ចឹងមធ្យោបាយធ្វើដំណើរមានដូចជាឡាន មានដូចជាឡានក្រុង
មានដូចជាម៉ូតូ មានដូចជាកង់ មានដូចជារថភ្លើង និងមានដូចជាម៉ូតូឌុប។ អញ្ចឹងពេលខ្លះ
ប្រសិនបើគាត់ត្រូវទៅណាដែលជិតល្មម មិនសូវឆ្ងាយពេក ហើយគាត់អត់មានឡាន
ឬក៏អត់មានម៉ូតូផ្ទាល់ខ្លួន គាត់អាចជិះម៉ូតូឌុបទៅបាន អញ្ចឹងម៉ូតូឌុប គឺនៅតាមផ្លូវ គឺមានច្រើន
យើងអាចឃើញម៉ូតូឌុបច្រើននៅតាមផ្លូវនៅក្នុងប្រទេសកម្ពុជា។

ដែលឥឡូវនេះ យើងមកមើលរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានស្ត្រីម្នាក់ ឬក៏នារីម្នាក់
ដែលមើលទៅវ័យគាត់ប្រហែលជាម្ភៃប្រាំឆ្នាំ ដែលស្ត្រីម្នាក់នោះ គាត់ពាក់ឯកសណ្ឋានជាអ្នកធ្វើការ
ដោយយើងឃើញគាត់ពាក់អាវដៃវែងពណ៌ខៀវ ហើយស្លៀកសំពត់ត្រឹមជង្គង់
ហើយពណ៌រៀងប្រផេះបន្តិច។ អញ្ចឹងស្ត្រីម្នាក់នោះគាត់មានសក់ត្រឹមស្មា ដែលគាត់កាត់សក់ត្រឹមស្មា
ហើយនៅដៃខាងស្តាំរបស់គាត់ យើងឃើញគាត់មានយួរកាបូបមួយពណ៌ស
អញ្ចឹងគាត់មានយួរកាបូបធំមួយពណ៌ស ដែលគាត់ដាក់នៅលើស្មា យើងឃើញគាត់ដាក់នៅលើស្មា
ក៏ប៉ុន្តែដៃស្តាំរបស់គាត់ គឺកាន់កាបូបគាត់យ៉ាងជាប់ គឺគាត់កាន់កាបូបគាត់យ៉ាងជាប់
ដោយគាត់ខ្លាចកាបូបគាត់ជ្រុះពីស្មារបស់គាត់។ ព្រោះថាប្រសិនបើ
បើទោះជាគាត់ស្ពាយកាបូបនោះនៅនឹងស្មាក៏ដោយ ក៏វាអាចនឹងរអិលធ្លាក់ដែរ ប្រសិនវាអត់
បើយើងអត់កាន់វានោះទេ ព្រោះថានៅពេលដែលយើងដើរ កាបូបនឹងយោល
អញ្ចឹងប្រសិនបើយើងអត់ទប់ ឬក៏អត់កាន់វាទេ កាបូបអាចធ្លាក់ពីស្មារបស់យើងបាន
ចំណែកឯដៃឆ្វេងរបស់នារីម្នាក់នោះ គឺគាត់ពាក់នាឡិកាដៃ អញ្ចឹងនាឡិកា គាត់ពាក់នៅនឹងដៃ
សម្រាប់មើលម៉ោង ដែលនាឡិកា ជាទូទៅ គឺមាននាឡិកាប្រភេទជាលោតលេខ យើងហៅថា
នាឡិកាអូតូម៉ាទិច និងមួយទៀតគឺជានាឡិកាមានទ្រនិច
អញ្ចឹងពេលខ្លះយើងអាចពាក់ជានាឡិកាលោតលេខ ឬក៏ពាក់ជានាឡិកាមានទ្រនិចជាដើម។
អញ្ចឹងនាឡិកា យើងជាទូទៅ យើងពាក់ដៃឆ្វេង ដើម្បីមើលម៉ោង។ អញ្ចឹងនៅក្នុងរូបភាពនេះ
នារីម្នាក់នោះគាត់កំពុងតែមើលម៉ោងនៅលើនាឡិកាដៃរបស់គាត់
ដោយគាត់ប្រហែលជាប្រញាប់យ៉ាងខ្លាំង ដោយយើងឃើញគាត់ធ្វើទឹកមុខប្រញាប់
ហើយមានអារម្មណ៍ថាជិតដល់ម៉ោង ឬក៏គាត់ជិតដល់ម៉ោងណាត់អ្វីមួយ
ឬក៏គាត់ណាត់ជួបជាមួយមិត្តភក្តិ ឬក៏ជួបជាមួយនឹង ដៃគូការងាររបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏ប៉ុន្តែដោយសារតែកៀកម៉ោងពេក ដូច្នេះយើងឃើញអាកប្បកិរិយារបស់គាត់
ឬក៏កាយវិការរបស់គាត់មានលក្ខណៈប្រញាប់ ដោយយើងឃើញគាត់ដើរបណ្ដើរ
និងមើលនាឡិកាបណ្ដើរ ដោយទឹកមុខប្រញាប់ប្រញាល់យ៉ាងខ្លាំង។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា នារីម្នាក់នោះ
គាត់ប្រហែលជារស់នៅក្នុងទីក្រុង ព្រោះថាយើងឃើញមានឡានជាច្រើននៅតាមផ្លូវ
កំពុងតែបើកបរនៅតាមផ្លូវ ក៏ប៉ុន្តែឡានទាំងអស់នោះគឺមិនបានទៅលឿននោះទេ
គឺទៅមុខអត់លឿននោះទេ ដោយសារតែវាស្ទះផ្លូវយ៉ាងខ្លាំង។ អញ្ចឹងនៅលើចំហៀងផ្លូវម្ខាង
នៅលើចំហៀងផ្លូវម្ខាង យើងឃើញស្រមោលរបស់នារីម្នាក់នោះ ដោយសារតែយើងមើលពីចម្ងាយ
ដូច្នេះយើងឃើញរូបនារីម្នាក់នោះគឺមានពណ៌ខ្មៅ អញ្ចឹងយើងឃើញគាត់កំពុងតែស្ពាយកាបូប
ហើយរត់បណ្ដើរ អញ្ចឹងដៃគាត់ម្ខាងគាត់កាន់កាបូបស្ពាយនៅនឹងស្មា
ហើយគាត់កំពុងតែរត់បណ្ដើរដោយអាការៈប្រញាប់ ព្រោះថាគាត់ជិះឡានអត់កើតទេ
ឬក៏គាត់ជិះរថយន្ត ឬក៏គាត់ជិះតាក់ស៊ីអត់បាន ព្រោះថាស្ទះផ្លូវខ្លាំងពេក
អញ្ចឹងឡានទៅមុខអត់រួចនោះទេ អញ្ចឹងដើម្បីឲ្យទាន់ម៉ោង ព្រោះគាត់កំពុងតែប្រញាប់
ដូច្នេះគាត់ត្រូវតែរត់ឲ្យលឿនទៅមុខ ប្រសិនបើគាត់ចាំឡាន គឺវាអាចយូរ អញ្ចឹងវាអាចយូរ
អញ្ចឹងអាចធ្វើឲ្យគាត់ខកម៉ោងបាន គាត់អត់អាចណាត់ជួបគេបានទាន់ពេល
អញ្ចឹងគាត់ត្រូវតែរត់នៅលើផ្លូវវិញ គាត់អត់ជិះឡាន ឬក៏អត់ជិះតាក់ស៊ីនោះទេ។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ បន្ទាប់ពីនារីម្នាក់នោះ
គាត់រត់បានមួយសន្ទុះក្រោយមក គាត់ក៏មកដល់រោងមួយ អញ្ចឹងគាត់ឈរនៅខាងមុខរោងមួយ
ដោយគាត់ ដៃខាងស្ដាំរបស់គាត់ គាត់ស្ពាយកាបូប ហើយដៃខាងស្ដាំរបស់គាត់
គឺទប់កាបូបគាត់យ៉ាងជាប់ ដោយគាត់កំពុងតែឈរទៅក្នុងសម្លឹងរោងមួយ ដែលនៅក្នុងរោងនោះ
យើងឃើញមានដំបូល ប៉ុន្តែអត់មានជញ្ជាំងនោះទេ អញ្ចឹងរោងនោះគឺជារោងម៉ូតូឌុប
ដោយយើងឃើញមានម៉ូតូចំនួនពីរគ្រឿងនៅខាងក្រោមរោងនោះ ហើយមានបុរសម្នាក់
ដែលជាម្ចាស់ម៉ូតូ កំពុងតែឈរផ្អែកម៉ូតូរបស់គាត់ អញ្ចឹងបុរសម្នាក់នោះគាត់ពាក់អាវដៃខ្លី
ខោជើងវែងពណ៌ស ហើយគាត់ ម៉ូតូរបស់គាត់គឺមានពណ៌ទឹកក្រូច។
អញ្ចឹងម៉ូតូរបស់គាត់គឺមានកង់ពីរ ហើយមានមួកការពារនៅលើនោះផងដែរ
អញ្ចឹងគាត់គឺជាអ្នករត់ម៉ូតូឌុប ដោយនារីម្នាក់នោះគាត់មានអាការៈប្រញាប់ ដោយសារតែស្ទះផ្លូវ
ជិះឡានអត់កើត អញ្ចឹងគាត់រត់ នៅពេលដែលគាត់រត់បានមួយភ្លែតមក
គឺគាត់បានមកដល់កន្លែងម៉ូតូឌុបមួយដែលមានរោង មានដំបូលពណ៌ផ្កាឈូក ហើយមានបុរសម្នាក់
គាត់កំពុងតែឈរផ្អែកម៉ូតូដើម្បីរង់ចាំម៉ូយ ឬក៏រង់ចាំអតិថិជនរបស់គាត់។ អញ្ចឹងនារីម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានឈប់នៅត្រង់រោងនោះ ហើយសម្លឹងទៅមើលម៉ូតូឌុប ដែលមានបុរសម្នាក់នោះកំពុងតែឈរផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បន្ទាប់ពីមកដល់រោងកន្លែងម៉ូតូឌុបរួចរាល់ហើយ នារីម្នាក់នោះ គាត់ក៏បានចូលទៅនិយាយជាមួយនឹងបុរសដែលពាក់អាវសដៃខ្លី ដែលជាម្ចាស់ម៉ូតូនោះ អញ្ចឹងប្រហែលជាគាត់អាចកំពុងតែនិយាយអំពីការធ្វើដំណើរទៅកន្លែងផ្សេងទៀត ឬក៏អាចនិយាយអំពីថ្លៃឈ្នួលធ្វើដំណើរ ព្រោះថាបុរសម្នាក់នោះគាត់គឺជាអ្នករត់ម៉ូតូឌុប អញ្ចឹងមុនពេលដែលទៅណាមកណា គឺយើង នៅពេលដែលយើងចង់ជិះម៉ូតូឌុប យើងត្រូវតែសួរម្ចាស់ម៉ូតូសិន ថាតើគាត់ទៅកន្លែងនេះ គាត់យកតម្លៃប៉ុន្មាន ដើម្បីយើងតថ្លៃ។ អញ្ចឹងនារីម្នាក់នោះគាត់កំពុងតែតថ្លៃ ដោយយើងឃើញដៃស្តាំរបស់គាត់ គឺកាន់កាបូបយ៉ាងជាប់ដដែល ចំណែកដៃឆ្វេងកំពុងតែចង្អុល អញ្ចឹងនារីម្នាក់នោះ គាត់និយាយបណ្តើរ គាត់ចង្អុលបណ្តើរ បានន័យថាគាត់កំពុងតែប្រាប់ទិសដៅដែលគាត់ចង់ទៅ ទៅដល់ម្ចាស់ម៉ូតូ។ អញ្ចឹងគាត់ចង់ដឹងថា តើម៉ូតូឌុបនោះ ឬក៏ម្ចាស់ម៉ូតូនោះ គាត់ស្គាល់ទីតាំងនោះដែរឬទេ ហើយពីកន្លែងនេះទៅដល់ទីតាំងឬក៏គោលដៅរបស់គាត់ តើម៉ូតូឌុបនោះ គាត់យកប៉ុន្មាន គាត់យកតម្លៃប៉ុន្មាន អញ្ចឹងនារីម្នាក់នោះគាត់ក៏បាននិយាយបណ្តើរ ចង្អុលបណ្តើរ ធ្វើកាយវិការបណ្តើរ ទៅកាន់បុរសដែលជាម្ចាស់ម៉ូតូ ចំណែកឯបុរសដែលជាម្ចាស់ម៉ូតូ គាត់ឈរឱបដៃ អញ្ចឹងយើងឃើញគាត់ឈរឱបដៃរបស់គាត់ ហើយគាត់កំពុងតែធ្វើមុខសញ្ជឹងគិត អញ្ចឹងគាត់កំពុងតែគិត ថាតើគាត់គួរតែយកតម្លៃប៉ុន្មាន ដើម្បីស័ក្តិសមនឹងប្រវែង ឬក៏ចម្ងាយ ដែលគាត់នឹងជិះទៅគោលដៅរបស់នារីម្នាក់នោះ។ អញ្ចឹងគាត់ស្តាប់បណ្តើរ គាត់គិតបណ្តើរ ដើម្បីយកតម្លៃមួយដែលស័ក្តិសម មិនថ្លៃពេក ហើយក៏មិនថោកពេកផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីនារីម្នាក់នោះ គាត់បានរៀបរាប់អំពីគោលដៅដែលគាត់ត្រូវទៅរួចហើយ រៀបរាប់អំពីគោលដៅដែលគាត់ត្រូវទៅ ប្រាប់ទៅដល់បុរសដែលជាម្ចាស់ម៉ូតូនោះរួចរាល់ហើយ បុរសម្ចាស់ម៉ូតូក៏បានគិតមួយសន្ទុះ បន្ទាប់មកគាត់ក៏បាននិយាយអំពីតម្លៃដែលគាត់នឹងយក ដើម្បីក្នុងការធ្វើដំណើរទៅ អញ្ចឹងពេលនោះ នារីម្នាក់នោះ គាត់ក៏បានយល់ព្រមជាមួយនឹងតម្លៃ ហើយបុរសដែលជាម្ចាស់ម៉ូតូ គាត់ក៏បានយល់ព្រមជូននារីនោះទៅផងដែរ។ អញ្ចឹងនៅក្នុងរូបភាពទី ៥ នេះ យើងឃើញពួកគេទាំងពីរអ្នកគឺមានទឹកមុខសប្បាយរីករាយ ដោយសារតែនារីម្នាក់នោះ គាត់កំពុងតែប្រញាប់ ហើយស្ទះផ្លូវ ដូច្នេះគាត់ជិះឡានអត់កើត អញ្ចឹងគាត់ក៏បានមករកម៉ូតូឌុប ដើម្បីទៅឲ្យបានលឿន ព្រោះម៉ូតូឌុបតូច ម៉ូតូតូច អញ្ចឹងងាយស្រួលជិះជាងឡាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយបុរសម្នាក់នោះ គាត់កំពុងតែរង់ចាំអតិថិជនដើម្បីជិះម៉ូតូឌុបរបស់គាត់
អញ្ចឹងនៅពេលដែលអតិថិជនរបស់គាត់មករកគាត់ គាត់សប្បាយរីករាយ ព្រោះថាគាត់
អាចរកអតិថិជនបាន ដូច្នេះគាត់នឹងបានលុយ ចំណែកឯនារីម្នាក់នោះ គាត់សប្បាយចិត្ត
ដោយសារតែគាត់អាចទៅទាន់ម៉ោង គាត់សង្ឃឹមថាគាត់ទៅទាន់ម៉ោង មិនខកណាត់នោះទេ។
អញ្ចឹងពួកគេទាំងពីរនាក់ ដែលនៅក្នុងរូបភាពទី ៥ នេះ គឺសប្បាយចិត្តដូចគ្នា
ដោយយើងឃើញទឹកមុខរបស់នារីម្នាក់នោះកំពុងតែញញឹម អញ្ចឹងគាត់ញញឹមហើយសើចសប្បាយ
ចំណែកឯបុរសដែលជាម្ចាស់ម៉ូតូ គាត់បានលើកដៃស្តាំឡើង ដើម្បីជាសញ្ញាថា
គាត់យល់ព្រមឌុបនារីម្នាក់នោះទៅកាន់គោលដៅរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា
បន្ទាប់ពីពួកគេយល់ព្រមគ្នាជិះទៅកាន់គោលដៅផ្សេងមួយទៀតនៅក្នុងតម្លៃមួយហើយ
បុរសដែលជាម្ចាស់ម៉ូតូ គាត់ក៏បានពាក់មួកការពារ ឬក៏មួកសុវត្ថិភាព
អញ្ចឹងយើងឃើញមួកគឺមានច្រើនប្រភេទ ដែលយើង មួកការពារកម្តៅថ្ងៃ
និងមួយទៀតគឺមួកការពារសុវត្ថិភាព។ អញ្ចឹងមួកការពារសុវត្ថិភាព
គឺយើងពាក់នៅពេលដែលយើងជិះម៉ូតូ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗដែលប៉ះពាល់ដល់ក្បាល។
អញ្ចឹងពេលខ្លះយើងអាចជិះម៉ូតូលឿន ឬក៏មិនប្រុងប្រយ័ត្នវាអាចដួល
អញ្ចឹងវាអាចធ្វើឲ្យយើងប៉ះពាល់ដល់ក្បាលរបស់យើង ដូច្នេះហើយនៅពេលដែលយើងជិះម៉ូតូ
យើងត្រូវតែពាក់មួកសុវត្ថិភាព។ ដែលជាក់ស្តែងបុរសដែលជាម្ចាស់ម៉ូតូនេះ
គាត់បានពាក់មួកសុវត្ថិភាពរបស់គាត់ពណ៌លឿង ដោយយើងឃើញមួកសុវត្ថិភាព
គឺមានកញ្ចក់មួយសម្រាប់បិទបើកផងដែរ ព្រោះពេលខ្លះដីហុយពេក យើងពិបាកនឹងមើលផ្លូវ
ដូច្នេះយើងគ្រាន់តែបិទកញ្ចក់ អញ្ចឹងដីអត់ហុយចូលភ្នែកយើងទេ ដូច្នេះ
ប៉ុន្តែនៅពេលដែលផ្លូវស្រឡះ អត់មានដី យើងអាចបើកកញ្ចក់បាន ដើម្បីឲ្យមើលកាន់តែច្បាស់។
អញ្ចឹងបុរសម្នាក់នោះ គាត់ពាក់មួកការពារខ្លួនឯងផង
និងគាត់លើកមួកការពារមួយទៀតទៅឲ្យនារីម្នាក់នោះ
ដោយយើងឃើញដៃស្តាំរបស់គាត់កំពុងតែចង្អុលទៅកាន់មួកការពារ ចំណែកដៃឆ្វេងរបស់គាត់
គឺកាន់មួកការពារនោះលើកឡើង ដើម្បីឲ្យទៅនារីម្នាក់នោះ
ឬក៏គាត់ណែនាំប្រាប់ឲ្យនារីម្នាក់នោះពាក់មួកសុវត្ថិភាព ឬក៏ពាក់មួកការពារ ដើម្បីកុំឲ្យមានគ្រោះថ្នាក់
ឬក៏ដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់ផ្សេងៗនៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍
ក៏ប៉ុន្តែនារីម្នាក់នោះ គាត់បានលើកដៃឡើង ដោយគាត់ថាមិនចង់ពាក់
គាត់អត់ចង់ពាក់មួកការពារនោះទេ។ អញ្ចឹងគាត់បានលើកដៃឆ្វេងរបស់គាត់ឡើង
ហើយគាត់បានបិទភ្នែក និងនិយាយប្រាប់ទៅបុរសដែលជាម្ចាស់ម៉ូតូថា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់អត់ចង់ពាក់មួកការពារសុវត្ថិភាពនោះទេ ដោយសារតែគាត់គិតថា ផ្លូវនោះគឺជិត និងគាត់គិតថាមិនមានគ្រោះថ្នាក់អ្វីនោះទេ ដូច្នេះគាត់អត់ចង់ពាក់ទេ ក៏ប៉ុន្តែជាទូទៅ ការពាក់មួកសុវត្ថិភាព គឺថែរក្សាសុវត្ថិភាពរបស់យើង ហើយមិនខុសច្បាប់ទៀត ក៏ប៉ុន្តែប្រសិនបើយើងជិះម៉ូតូ អត់ពាក់មួកសុវត្ថិភាពនោះទេ គឺវាខុសនឹងច្បាប់ចរាចរណ៍ ដូច្នេះប្រសិនបើប៉ូលិសឃើញ ប៉ូលិសអាចផាកពិន័យយើងបាន។ អញ្ចឹងយើងអាចខាតបង់ប្រាក់ ដោយសារតែប៉ូលិសផាកពិន័យ ដោយសារតែយើងមិនអាច មិនបានពាក់មួកសុវត្ថិភាព ហើយយើងអាចមានគ្រោះថ្នាក់ផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ គាត់បាននិយាយជាមួយនឹងបុរសដែលជាម្ចាស់ម៉ូតូហើយ ពួកគេទាំងពីរនាក់ក៏បានឡើងលើម៉ូតូ ដើម្បីជិះទៅកាន់គោលដៅរបស់គេ ដោយយើងឃើញបុរសដែលជាម្ចាស់ម៉ូតូ គាត់អង្គុយខាងមុខ ហើយគាត់កំពុងតែកាន់ចង្កូតម៉ូតូ ដោយគាត់ពាក់អាវពណ៌សដៃខ្លី ខោសជើងវែង និងគាត់មានពាក់មួកសុវត្ថិភាពពណ៌លឿងមួយ ដែលយើងឃើញគាត់កំពុងតែបិទកញ្ចក់ អញ្ចឹងមួកសុវត្ថិភាពរបស់គាត់ គឺមានកញ្ចក់ ដូច្នេះនៅពេលដែលគាត់ជិះ គាត់អត់ចង់ឲ្យខ្យល់ ឬក៏ដីហុយចូលភ្នែករបស់គាត់ទេ អញ្ចឹងគាត់អាចបិទកញ្ចក់បាន។ ដោយកញ្ចក់គឺជាកញ្ចក់ថ្លា ដូច្នេះគាត់អាចមើលឃើញឆ្លុះពីក្នុងមួកទៅក្រៅបាន អញ្ចឹងវាអត់មានបាំង ឬក៏អត់មានប៉ះពាល់ទេ អញ្ចឹងគាត់អាចមើលបាន។ ហើយយើងឃើញម៉ូតូរបស់គាត់ គឺមានកញ្ចក់សម្រាប់មើលក្រោយផងដែរ ដែលនៅក្បែរចង្កូតម៉ូតូ។ អញ្ចឹងកញ្ចក់សុវត្ថិភាព យើងហៅថាកញ្ចក់សុវត្ថិភាព គឺជាកញ្ចក់ដែលអាចឲ្យយើងមើលក្រោយបាន អញ្ចឹងយើងអត់ចាំបាច់ងាកទេ នៅពេលដែលយើងចង់វ៉ា ឬក៏ចង់បត់ផ្សេងៗ យើងអត់ចាំបាច់ងាកក្រោយទេ យើងគ្រាន់តែមើលទៅតាមកញ្ចក់ នោះយើងអាចនឹង យើងអាចមើលឃើញអ្វីដែលនៅខាងក្រោយម៉ូតូរបស់យើងបាន។ ហើយនៅខាងមុខម៉ូតូ គឺមានចង្កៀងមួយ អញ្ចឹងជាទូទៅម៉ូតូតែងតែមានចង្កៀងមួយសម្រាប់បំភ្លឺផ្លូវ ដែលយើងអាចជិះបំភ្លឺផ្លូវនៅពេលដែលពេលយប់ ឬក៏ពេលដែលមានភ្លៀងខ្លាំង ឬក៏ពេលដែលមានដីហុយខ្លាំង អញ្ចឹងយើងអាចបើកភ្លើង ដើម្បីបំភ្លឺផ្លូវ ដូច្នេះគ្រប់ម៉ូតូទាំងអស់ គឺតែងតែមានភ្លើង ដើម្បីបំភ្លឺផ្លូវនៅខាងមុខ និងនៅខាងក្រោយ ដើម្បីឲ្យអ្នកដែលជិះពីក្រោយយើងមើលឃើញយើង។ ហើយម៉ូតូជាទូទៅគឺមានកង់ពីរ គឺអត់ដូចឡានទេ ឡានគឺមានកង់បួន ចំណែកម៉ូតូគឺមានកង់តែពីរតែប៉ុណ្ណោះ អញ្ចឹងយើងឃើញបុរសដែលជាម៉ូតូឌុបនោះ ឬក៏ជាអ្នករត់ម៉ូតូឌុប គាត់ជិះខាងមុខ រីឯស្ត្រីដែលមានវ័យប្រហែល ២៥ ឆ្នាំនោះ គាត់ជិះខាងក្រោយ ក៏ប៉ុន្តែគាត់ជិះពាក់ឆៀង ឬក៏ជិះចំហៀង។ អញ្ចឹងយើងឃើញគាត់អង្គុយដោយដាក់ជើងទាំងពីររបស់គាត់មកម្ខាង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថាគាត់អត់ជិះច្រកគាវទេ ដែលមនុស្សប្រុស គេជិះ ពីក្រោយគឺគេជិះច្រកគាវ ចំណែកមនុស្សស្រី ដោយសារតែគាត់ស្លៀកសំពត់ ដូច្នេះគាត់ជិះច្រកគាវដូចមនុស្សប្រុសអត់កើតទេ អញ្ចឹងគាត់ជិះចំហៀង ដោយគាត់អង្គុយលើកែបម៉ូតូ ក៏ប៉ុន្តែជើងគាត់ទាំងពីរដាក់មកម្ខាង។ ដោយយើងឃើញជាក់ស្តែងនៅក្នុងរូបភាពទី ៧ នេះ គឺនារីម្នាក់នោះគាត់អង្គុយ ហើយដាក់កាបូបរបស់គាត់ គាត់អត់ស្ពាយទៀតទេ គឺគាត់ដាក់កាបូបធំរបស់គាត់ នៅលើភ្លៅរបស់គាត់ ដោយដៃទាំងពីររបស់គាត់កំពុងតែកាន់កាបូបគាត់យ៉ាងជាប់ ដោយខ្លាចជ្រុះ ឬក៏ដោយខ្លាចធ្លាក់ ហើយភ្នែករបស់គាត់គឺសម្លឹងទៅខាងមុខ អញ្ចឹងគាត់សម្លឹងទៅកាន់គោលដៅរបស់គាត់ ដើម្បីប្រាប់ផ្លូវទៅដល់ម្ចាស់ម៉ូតូថា តើត្រូវជិះតាមផ្លូវណាខ្លះ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថាម៉ូតូក៏បានជិះនៅតាមផ្លូវ ដែលយើងឃើញមានឡានជាច្រើន អញ្ចឹងមានឡានជាច្រើនកំពុងតែធ្វើដំណើរនៅតាមផ្លូវ ប៉ុន្តែដោយសារតែថ្ងៃនោះ គឺជាថ្ងៃធ្វើការ ដូច្នេះមានមនុស្សច្រើនជិះធ្វើដំណើរនៅតាមផ្លូវ អញ្ចឹងវាធ្វើឲ្យឡានស្ទះ ឬក៏បើកបរយឺតៗ មិនអាចទៅលឿនបាននោះទេ។ ដូច្នេះម៉ូតូ នៅពេលដែលយើងជិះម៉ូតូ គឺអាចមានផ្លូវស្រឡះ ងាយស្រួលជិះ ដោយសារតែម៉ូតូគឺមានរាងតូចជាងឡាន អញ្ចឹងម៉ូតូអាចចាក់តាមប្រឡោះតូចៗបាន ឬក៏ជ្រែតាមប្រឡោះតូចៗ។ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៨ នេះ យើងឃើញបុរសដែលជាម៉ូតូឌុប ជាម្ចាស់ម៉ូតូនោះ គាត់បានឌុបនារីម្នាក់នោះ ដោយជិះយ៉ាងលឿន គឺគាត់បានជ្រែឡាន ពីឆ្វេងមកស្តាំ ពីស្តាំមកឆ្វេង គឺគាត់គេចឡាន ហើយរកផ្លូវស្រឡះ ដើម្បីជិះឲ្យបានលឿន ព្រោះនារីម្នាក់នោះ គឺគាត់កំពុងតែប្រញាប់ ដូច្នេះហើយបុរសម្នាក់នោះ គាត់ត្រូវតែជិះ ជ្រែផង វ៉ាផង ធ្វើយ៉ាងណា លឿន តាមដែលអាចធ្វើទៅបាន។ អញ្ចឹងគាត់ប្រឹងប្រែងជិះឲ្យបានលឿន ដើម្បីកុំឲ្យខកម៉ោង ឬក៏ខកណាត់របស់នារី ដែលជាអតិថិជនរបស់គាត់ ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺគាត់បានជ្រែឡាន ទៅឆ្វេងផង ទៅស្តាំផង ដើម្បីរកផ្លូវស្រឡះ ដើម្បីជិះទៅខាងមុខឲ្យបានលឿន។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញ នៅពេលដែលគាត់ជិះជ្រែឡានបានបន្តិចក្រោយមក នារីម្នាក់នោះ គាត់ក៏បានចង្អុល ប្រាប់ទៅបុរសម្នាក់នោះថា គោលដៅរបស់គាត់គឺនៅខាងមុខ ដូច្នេះគាត់ចង់ឲ្យបុរសម្នាក់នោះអែបទៅឆ្វេង ឬក៏អែបទៅស្តាំ ដើម្បីឲ្យគាត់ចុះ។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ បុរសដែលជាម៉ូតូឌុបនោះ គាត់បានកំពុងតែអង្គុយ កាន់ចង្កូតម៉ូតូ ហើយបញ្ជាម៉ូតូរបស់គាត់ទៅមុខយ៉ាងលឿន ចំណែកឯនារីម្នាក់នោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានលើកដៃឆ្វេងគាត់ឡើង អញ្ចឹងគាត់លើកដៃឆ្វេងរបស់គាត់ឡើង ហើយចង្អុលទៅខាងមុខ
ដោយចង្អុលប្រាប់ទៅម្ចាស់ម៉ូតូ ដើម្បីប្រាប់ថា គាត់មកដល់គោលដៅហើយ
ដូច្នេះឲ្យម្ចាស់ម៉ូតូគាត់រកកន្លែងឈប់ ដើម្បីឲ្យនារីម្នាក់នោះគាត់ចុះ ព្រោះគាត់បានមកដល់គោលដៅ
ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះ គាត់បានលើកដៃឆ្វេងចង្អុលទៅខាងមុខ
ចំណែកដៃស្ដាំរបស់គាត់ គឺគាត់នៅតែកាន់កាបូបរបស់គាត់ដែលនៅលើភ្លៅយ៉ាងជាប់
ព្រោះគាត់ខ្លាចជ្រុះកាបូប ដោយសារតែកាបូបរបស់គាត់ជាកាបូបធំ
អញ្ចឹងគាត់អត់បានស្ពាយនៅលើស្មាទេ នៅពេលដែលគាត់ជិះម៉ូតូ ដូច្នេះគាត់ត្រូវដាក់លើភ្លៅ
ហើយដៃរបស់គាត់ត្រូវតែកាន់កាបូបនោះឲ្យជាប់ ប្រសិនបើកាន់អត់ជាប់ទេ
កាបូបនោះអាចនឹងរអិលធ្លាក់ ដូច្នេះទ្រព្យសម្បត្តិរបស់គាត់ មានដូចជាលុយ
មានដូចជាទូរស័ព្ទផ្សេងៗ គឺអាចនឹងបាត់បង់ នៅពេលដែលកាបូបនោះជ្រុះពីលើខ្លួនរបស់គាត់
ឬក៏ជ្រុះពីលើម៉ូតូ។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០
បន្ទាប់ពីទទួលបានការប្រាប់ពីនារីម្នាក់នោះហើយ បុរសដែលជាម្ចាស់ម៉ូតូឌុប
គាត់ក៏បានអែបទៅឆ្វេង អញ្ចឹងគាត់ក៏បានជិះម៉ូតូអែបទៅឆ្វេង អែបទៅរកចិញ្ចើមថ្នល់
អញ្ចឹងអម្បាញ់មិញគឺគាត់ជិះនៅកណ្ដាលថ្នល់ ដោយសារតែគាត់ប្រញាប់ ដូច្នេះគាត់ជិះជ្រែចុះ
ជ្រែឡើង វ៉ាទ្បានផង ហើយនៅកណ្ដាលថ្នល់ អញ្ចឹងនៅពេលដែលជិតមកដល់គោលដៅ
នារីម្នាក់នោះគាត់ក៏បានចង្អុលប្រាប់ទៅបុរសម្នាក់នោះថា ឲ្យឈប់នៅគោលដៅខាងមុខ
ដោយអែបឆ្វេង អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានអែបមកខាងឆ្វេង [រក] មករកចិញ្ចើមថ្នល់
ដើម្បីឈប់ ព្រោះយើងអត់អាចឈប់ម៉ូតូនៅកណ្ដាលថ្នល់បាននោះទេ
ព្រោះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន ព្រោះនៅពេលដែលយើងឈប់នៅកណ្ដាលថ្នល់
វាអាចធ្វើឲ្យទ្បាន ឬក៏ម៉ូតូផ្សេងទៀត [មក] បើកមកបុកពីក្រោយ
ដូច្នេះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ អញ្ចឹងនៅពេលដែលយើងចង់ឈប់ យើងត្រូវតែស៊ីញ៉ូឆ្វេង
ឬក៏ស៊ីញ៉ូស្ដាំ ហើយអែបមកឆ្វេង ឬក៏អែបទៅស្ដាំតាមដែលយើងចង់ឈប់ ព្រោះថាពេលខ្លះយើងត្រូវ
គោលដៅរបស់យើង គឺនៅខាងឆ្វេងដៃ ហើយពេលខ្លះគោលដៅគឺនៅខាងស្ដាំដៃ
ដូច្នេះនៅពេលដែលយើងចង់ឈប់ ឬក៏អែបទៅឆ្វេង ឬក៏អែបទៅស្ដាំ យើងត្រូវវាយស៊ីញ៉ូ
ឬក៏យើងបើកភ្លើងស៊ីញ៉ូ ដើម្បីឲ្យអ្នកដទៃដឹងថា យើងចង់ឈប់។ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ
គឺគាត់បានអែបមកឆ្វេង ដោយសារតែនារីម្នាក់នោះ គាត់ឲ្យបុរសដែលជាម្ចាស់ម៉ូតូ អែបមកឆ្វេង
ព្រោះថាគោលដៅរបស់គាត់គឺនៅខាងឆ្វេង។ អញ្ចឹងបុរសម្នាក់នោះ
គាត់ក៏បានឈប់ម៉ូតូនៅខាងឆ្វេងដៃ នៅលើចិញ្ចើមថ្នល់ខាងឆ្វេង
ហើយគាត់ក៏បានទម្លាក់ជើងម្ខាងរបស់គាត់ដាក់ទៅលើដី ព្រោះថាដោយសារតែម៉ូតូមានកង់ពីរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះវាអត់អាចទប់លំនឹងជាប់នោះទេ អញ្ចឹងដើម្បីឲ្យម៉ូតូនឹង យើងត្រូវដាក់ជើងម្ខាងរបស់យើងជាន់ទៅលើដី ឬក៏ដាក់ជើងទាំងសងខាងជាន់ទៅលើដី នៅពេលដែលយើងឈប់ម៉ូតូ ព្រោះប្រសិនបើយើងអត់ដាក់ទេ វាអាចនឹងដួល ដោយសារតែម៉ូតូមានកង់ពីរ អញ្ចឹងវាអត់អាចទប់លំនឹងជាប់នោះទេ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា បន្ទាប់ពីនារី បុរសម្នាក់នោះគាត់បានឈប់ម៉ូតូរួចរាល់ហើយ អញ្ចឹងនារីម្នាក់នោះ គាត់ក៏បានហក់ចុះពីលើម៉ូតូភ្លាមៗផងដែរ។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញបុរសដែលជាម្ចាស់ម៉ូតូ គាត់បានប្រលែងដៃចង្កូតទាំងពីរនៃម៉ូតូរបស់គាត់ ដោយគាត់ដាក់ដៃម្ខាងនៅលើកែបខាងក្រោយ ហើយជើងម្ខាងរបស់គាត់ គឺទម្លាក់ចុះមកដី ដើម្បីទប់ម៉ូតូកុំឲ្យដួល។ ចំណែកឯនារីម្នាក់នោះ គឺគាត់បានលោតចេញពីលើកែបម៉ូតូ ដោយគាត់លោតចុះមកខាងក្រោម អញ្ចឹងយើងឃើញដៃទាំងពីររបស់គាត់ គឺកាន់កាបូបយ៉ាងជាប់ ហើយជើងទាំងពីររបស់គាត់ គឺលោតចុះមកក្រោម[មក]ជាន់នឹងដី ដោយគាត់លោតចេញពីម៉ូតូ ដោយសារតែម៉ូតូខ្ពស់ជាងគាត់បន្តិច ដូច្នេះជើងគាត់អត់ដល់ដីទេ អញ្ចឹងដើម្បីចុះពីលើម៉ូតូបាន គាត់មានតែលោតចេញពីម៉ូតូ ដោយយើងឃើញបុរសដែលជាម្ចាស់ម៉ូតូ គាត់ក៏បានងាកមើលនារីនោះផងដែរ ដោយសារតែគាត់ខ្លាចនារីម្នាក់នោះ គាត់លោតចុះ ហើយដួល ឬក៏មានគ្រោះថ្នាក់ ដូច្នេះគាត់បើកកញ្ចក់គាត់ ហើយអង្គុយមើលនារីម្នាក់នោះនៅពេលដែលគាត់ចុះពីម៉ូតូរបស់គាត់ ព្រោះគាត់ខ្លាចនៅពេលដែលប្រសិនបើនារីម្នាក់នោះ គាត់ចុះហើយដួល អញ្ចឹងគាត់អាចរត់ទៅជួយនារីម្នាក់នោះបាន ឬក៏គាត់ខ្លាចថា ពេលដែលគាត់ចុះពីម៉ូតូទៅ អាចមានឡាន ឬក៏មានម៉ូតូ ដែលជិះខាងក្រោយមកប៉ះ ឬក៏មក[កៀក ?]គាត់ ដូច្នេះអាចធ្វើឲ្យនារីម្នាក់នោះមានគ្រោះថ្នាក់។ អញ្ចឹងហើយគឺទើបនៅពេលដែលនារីម្នាក់នោះគាត់ចុះពីម៉ូតូ បុរសដែលជាម្ចាស់ម៉ូតូ គាត់បានតាមមើលនារីម្នាក់នោះ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ គាត់ចុះពីលើម៉ូតូហើយ គាត់ក៏បានលូកដៃចូលទៅក្នុងកាបូបធំរបស់គាត់ អញ្ចឹងគាត់យកកាបូបធំរបស់គាត់មកស្ពាយនៅលើដៃស្តាំវិញដដែល អញ្ចឹងគាត់បានស្ពាយនៅលើស្មាស្តាំ ហើយយកដៃស្តាំគាត់ទប់កាបូប ចំណែកដៃឆ្វេងរបស់គាត់ គឺគាត់កំពុងតែយកកាបូបលុយ លូកយកកាបូបលុយចេញពីកាបូបធំរបស់គាត់ ដោយយើងឃើញកាបូបលុយរបស់គាត់ គឺមានពណ៌ទឹកក្រូច អញ្ចឹងនៅពេលដែលមកដល់គោលដៅជាទូទៅ យើងតែងតែឲ្យលុយទៅដល់អ្នករត់ម៉ូតូឌុប ជាក់ស្តែងនៅក្នុងរូបភាពទី ១២ នេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺនារីម្នាក់នោះ គាត់កំពុងតែដកយកកាបូបលុយចេញពីកាបូបធំ ដើម្បីឲ្យលុយទៅកាន់ម៉ូតូឌុប ដោយម៉ូតូឌុបគាត់អង្គុយនៅលើម៉ូតូគាត់ធម្មតា ហើយក្បាលរបស់គាត់គឺពាក់មួកសុវត្ថិភាព ការពារសុវត្ថិភាព អញ្ចឹងគាត់អង្គុយចាំយកលុយពីអតិថិជន ដែលជានារីម្នាក់នោះ ដោយគាត់យកតម្លៃទៅតាមអ្វីដែលគាត់បាននិយាយគ្នានៅពេលមុន នៅពេលដែលគាត់ឡើងជិះម៉ូតូ។ ដូច្នេះហើយនៅពេលដែលមកដល់គោលដៅ នារីម្នាក់នោះ គាត់ក៏បានដកយកកាបូបលុយរបស់គាត់ចេញពីកាបូបធំ ដើម្បីឲ្យលុយទៅកាន់បុរសដែលជាម៉ូតូឌុបនោះ។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់ពីគាត់ដកយកកាបូបលុយមួយហើយ អញ្ចឹងគាត់ក៏បានយកលុយចេញពីកាបូបលុយរបស់គាត់ ហើយហុចទៅឲ្យបុរសដែលជាម្ចាស់ម៉ូតូឌុបនោះ អញ្ចឹងយើងឃើញដៃឆ្វេងរបស់នារីម្នាក់នោះ គាត់បានហុចលុយមួយសន្លឹកទៅឲ្យបុរសដែលជាម្ចាស់ម៉ូតូ ឬក៏ដែលជាអ្នករត់ម៉ូតូឌុប ដោយគាត់ឲ្យបណ្ដើរ និយាយបណ្ដើរ។ ប៉ុន្តែដោយសារតែលុយនោះគឺជាលុយជាប់ អញ្ចឹងគាត់អត់មានលុយរាយ ដោយសារតែនារីម្នាក់នោះ គាត់អត់មានលុយរាយ ដូច្នេះគាត់ក៏បានហុចលុយមួយសន្លឹកទៅឲ្យបុរសម្នាក់ដែលជាអ្នករត់ម៉ូតូឌុបនោះ ដោយគាត់ហុចបណ្ដើរ និងនិយាយទៅកាន់បុរសម្នាក់នោះបណ្ដើរថានេះជាលុយថ្លៃឈ្នួលម៉ូតូឌុប អញ្ចឹងបុរសដែលជាម្ចាស់ម៉ូតូ គាត់ក៏បានងាកមករកនារីម្នាក់នោះ ដោយសម្លឹងមុខនារីម្នាក់នោះ ហើយសម្លឹងបណ្ដើរ ដៃរបស់គាត់ទទួលយកលុយបណ្ដើរពីនារីម្នាក់នោះ។ អញ្ចឹងនៅពេលដែលបំពេញការងារចប់ អតិថិជនត្រូវតែឲ្យលុយទៅដល់អ្នករត់ម៉ូតូឌុប អញ្ចឹងនៅពេលដែលយើងជិះម៉ូតូ នៅពេលដែលដល់គោលដៅ យើងត្រូវតែឲ្យលុយអ្នករត់ម៉ូតូឌុប ដោយសារតែអ្នករត់ម៉ូតូឌុប គឺគាត់រត់ឌុបយើង ដើម្បីរកលុយ ឬក៏ដើម្បីរកប្រាក់។ អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពទី ១៣ នេះ នារីម្នាក់នោះគាត់ក៏បានឲ្យលុយទៅកាន់អ្នករត់ម៉ូតូឌុប បន្ទាប់ពីគាត់មកដល់គោលដៅរបស់គាត់ហើយ។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ ដោយសារតែនារីម្នាក់នោះ គាត់អត់មានលុយរាយ ដូច្នេះនារីម្នាក់នោះ គាត់ក៏បានឲ្យលុយជាប់ទៅឲ្យបុរស ដែលជាម្ចាស់ម៉ូតូឌុប។ អញ្ចឹងដោយសារតែតម្លៃលុយនោះ គឺវាច្រើនជាងអ្វីដែលបុរសដែលជាម្ចាស់ម៉ូតូឌុបត្រូវយក អញ្ចឹងគាត់ត្រូវអាប់លុយទៅឲ្យនារីម្នាក់នោះវិញ។ ដែលជាក់ស្ដែងយើងឃើញនៅក្នុងរូបភាពទី ១៤ នេះ គឺនៅពេលដែលបុរសដែលជាម្ចាស់ម៉ូតូនោះ គាត់បានទទួលយកលុយពីនារីម្នាក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលជាអតិថិជនរបស់គាត់ហើយ អញ្ចឹងគាត់ក៏បានយកកាក់ ឬក៏សេន មកអាប់ឲ្យនារីម្នាក់នោះវិញ
ដោយសារតែវា នារីម្នាក់នោះ គាត់ឲ្យលុយទៅលើសចំនួន ឬក៏លើសតម្លៃនៃការជិះម៉ូតឌុប។
ដូច្នេះប្រសិនបើយើងអត់លុយរាយ យើងឲ្យលុយជាប់ទៅគេ
ហើយលុយរបស់យើងគឺច្រើនជាងតម្លៃនៃអ្វីដែលយើងបានទិញ ឬក៏តម្លៃនៃម៉ូតូឌុប
ដែលយើងបាននិយាយគ្នា អញ្ចឹងអ្នកលក់ ឬក៏ម្ចាស់ម៉ូតូ គាត់តែងតែអាប់លុយមកឲ្យយើងវិញ
ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺបន្ទាប់ពីបុរសដែលជាម្ចាស់ម៉ូតូឌុប
គាត់បានទទួលយកលុយពីនារីម្នាក់នោះហើយ គាត់ក៏បានយកលុយមួយចំនួន ឬក៏កាក់មួយចំនួន
អាប់ត្រលប់ឲ្យនារីម្នាក់នោះវិញ ដោយយើងឃើញគាត់កាន់លុយនៅដៃឆ្វេង
ហើយដៃស្តាំគាត់ទម្លាក់កាក់ទៅឲ្យនារីម្នាក់នោះ។ អញ្ចឹងនារីម្នាក់នោះ
គាត់ក៏បានលើកដៃរបស់គាត់ទទួលយកប្រាក់អាប់មកពីបុរសដែលជាម្ចាស់ម៉ូតូវិញផងដែរ
ដោយយើងឃើញគាត់លើកដៃឆ្វេង ដើម្បីទទួលយកប្រាក់អាប់។ អញ្ចឹងពួកគេទាំងពីរអ្នក
ក៏បានឲ្យលុយគ្នាទៅវិញទៅមក ដោយម្ខាងឲ្យលុយ ម្ខាងទៀតទទួលយកប្រាក់អាប់។
អញ្ចឹងលុយដែលយើងអាប់មកពីលុយធំ លុយជាប់ អញ្ចឹងនៅពេលដែលយើងទិញទំនិញផ្សេងៗ
ដោយយើងឲ្យលុយធំ ឬក៏លុយជាប់ទៅ ហើយគេមានប្រាក់រាយត្រលប់មកវិញ
យើងហៅថាលុយអាប់។ អញ្ចឹងនារីម្នាក់នេះ នៅក្នុងរូបភាពទី ១៤ គឺគាត់កំពុងតែទទួលលុយអាប់។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីបានទទួលលុយ
និងប្រគល់លុយឲ្យគ្នារួចរាល់អស់ហើយ អញ្ចឹងបុរសដែលជាម្ចាស់ម៉ូតូ
គាត់បានបត់ម៉ូតូរបស់គាត់ត្រលប់ក្រោយ អញ្ចឹងគាត់បានបត់ម៉ូតូត្រលប់ក្រោយ ដើម្បីទៅរកទីតាំង
ឬក៏គោលដៅរបស់គាត់វិញ ដោយយើងឃើញអម្បាញ់មិញ គឺគាត់ចតនៅខាងឆ្វេង ឬក៏គាត់ចតនៅ
គាត់ឈប់នៅចិញ្ចើមថ្នល់ម្ខាង អញ្ចឹងប្រសិនបើគាត់ត្រលប់ក្រោយនៅកន្លែងដដែល
គឺបានន័យថាគាត់ជិះបញ្ច្រាសផ្លូវ អញ្ចឹងអត់ត្រឹមត្រូវនោះទេ ដូច្នេះគាត់ត្រូវតែជិះឆ្លងផ្លូវ
ដើម្បីមកចិញ្ចើមថ្នល់ម្ខាងទៀត ដើម្បីទៅជិះត្រលប់ក្រោយ។ ដោយសារតែជាទូទៅប្រទេសនីមួយៗ
ការធ្វើចរាចរណ៍ តែងតែប្រកាន់ឆ្វេង ឬក៏ប្រកាន់ស្តាំ ដែលជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា
គឺជាជិះប្រកាន់ស្តាំ អញ្ចឹងយើងអត់អាចជិះខាងឆ្វេងដៃបាននោះទេ ប្រសិនបើយើងជិះខាងឆ្វេងដៃ
គឺខុសនឹងច្បាប់ចរាចរណ៍ ម្យ៉ាងវិញទៀត ប្រសិនបើយើងជិះឆ្វេងដៃវាអាចមានគ្រោះថ្នាក់
ដោយសារតែយើងជិះបញ្ច្រាសផ្លូវ អញ្ចឹងយើងត្រូវជិះខាងស្តាំដៃជានិច្ចនៅក្នុងប្រទេសកម្ពុជា។
ចំណែកនៅក្នុងរូបភាពនេះ ប្រហែលជានៅប្រទេសថៃ
ព្រោះថាប្រទេសថៃគឺជាប្រទេសដែលប្រកាន់ឆ្វេង អញ្ចឹងនៅពេលដែលធ្វើចរាចរណ៍
គឺគេជិះបើកបរនៅខាងឆ្វេងដៃ។ ដែលជាក់ស្តែងយើងឃើញរូបភាពទី ១៥ នេះ
គឺបុរសដែលជាម្ចាស់ម៉ូតូនោះ គាត់បានជិះមកខាងឆ្វេងដៃ គាត់បានបើកម៉ូតូរបស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បត់មកខាងឆ្វេងដៃដើម្បីជិះត្រលប់ក្រោយទៅវិញ។ ចំណែកឯនារីម្នាក់នោះ គាត់
នៅពេលដែលគាត់ឲ្យលុយទៅដល់ម៉ូតូឌុបរួចរាល់ហើយ គាត់បានមើលនាឡិការបស់គាត់ម្តងទៀត
ដោយគាត់ដើរបណ្តើរ និងមើលនាឡិកាបណ្តើរ ហើយលើកនេះ គឺគាត់មានទឹកមុខញញឹម
ដោយគាត់មានទឹកមុខញញឹម ដោយគាត់គិតថា គាត់មកទាន់ម៉ោង ឬក៏គាត់ទាន់ម៉ោងណាត់។
ដោយយើងឃើញដៃរបស់គាត់កំពុងតែលើកឡើង ដៃឆ្វេងរបស់គាត់លើកឡើងដើម្បីមើលនាឡិកា
ហើយដៃស្តាំរបស់គាត់គឺទប់កាបូបធំរបស់គាត់ដែលស្ពាយនៅនឹងស្មា។
អញ្ចឹងគាត់មើលនាឡិកាបណ្តើរ គាត់ញញឹមបណ្តើរ ដោយសារតែគាត់អត់យឺតម៉ោងនោះទេ។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីគាត់ចុះពីលើម៉ូតូហើយ
គាត់ក៏បានដើរសំដៅមករកហាងកាហ្វេមួយ ដោយនៅក្នុងនោះយើងឃើញមិត្តភក្តិរបស់គាត់ម្នាក់
កំពុងតែអង្គុយនៅក្នុងហាងកាហ្វេនោះ។ អញ្ចឹងនារីម្នាក់នោះ គាត់ក៏បានដើរចូលមកតាមខ្លោងទ្វារ
ឬក៏តាមមាត់ទ្វារហាង ដោយយើងឃើញនៅក្បែរមាត់ទ្វារនោះ គឺមានរូបថតព្យួរជាច្រើន
ដែលរូបថតទាំងនោះ អាចជារូបគំនូរ ឬជារូបថត ដែលគេដាក់តាំងលម្អនៅក្នុងហាងកាហ្វេរបស់គេ។
អញ្ចឹងនារីម្នាក់នោះ គាត់បានដើរចូលតាមទ្វារ ហើយគាត់ដើរមកដល់ គាត់លើកដៃម្ខាងឡើង
ដើម្បីហៅមិត្តភក្តិរបស់គាត់ អញ្ចឹងគាត់លើកដៃឆ្វេងរបស់គាត់ឡើង
រីឯដៃស្តាំគឺគាត់នៅតែទប់កាបូបដែលស្ពាយនៅនឹងស្មា។
ចំណែកឯយើងឃើញមានបុរសម្នាក់ដែលកំពុងអង្គុយនៅលើកៅអី [នៅលើនឹង]តុ
នៅក្នុងហាងកាហ្វេនោះផងដែរ ដោយបុរសម្នាក់នោះ គាត់ពាក់អាវដៃខ្លីពណ៌លឿង
ស្លៀកខោជើងវែងពណ៌ស ហើយនៅលើតុរបស់គាត់គឺមានកែវកាហ្វេចំនួនមួយ
អញ្ចឹងបានន័យថាគាត់ណាត់ជាមួយនឹងនារីម្នាក់នោះ ដើម្បីមកញ៉ាំកាហ្វេនៅក្នុងហាងកាហ្វេ
ដើម្បីនិយាយគ្នាអំពីការងារ ឬក៏អំពីការសិក្សាផ្សេងៗ អញ្ចឹងនារីម្នាក់នោះគាត់ក៏បានមកដល់
ហើយពួកគេទាំងពីរនាក់ ក៏បានលើកដៃឡើង ដើម្បីជាសញ្ញាហៅគ្នាទៅវិញទៅមក។
ដោយយើងឃើញបុរសដែលជាអ្នកអង្គុយនៅក្នុងហាងកាហ្វេនោះ គឺគាត់លើកដៃទាំងពីរឡើង
ហើយគាត់ញញឹម បានន័យថាគាត់សប្បាយរីករាយ ដោយសារតែគាត់ឃើញនារីម្នាក់នោះ
ដែលជាមិត្តភក្តិរបស់គាត់ មកទាន់ការណាត់។ ហើយនៅក្បែរតុរបស់បុរសម្នាក់នោះ
យើងឃើញមានតុកាហ្វេចំនួនមួយទៀត អញ្ចឹងបានន័យថា ហាងកាហ្វេនោះគឺមានតុច្រើន
ដែលដាក់នៅក្បែរៗគ្នា ដោយយើងឃើញមានតុចំនួនមួយទៀតដែលនៅក្បែរនោះ
ហើយមានកែវកាហ្វេនៅលើតុនោះផងដែរ។ អញ្ចឹងពួកគេទាំងពីរអ្នកមកហាងកាហ្វេ ដើម្បីញ៉ាំកាហ្វេ
ជជែកគ្នាអំពីរឿងការសិក្សា អំពីការងារផងដែរ ដោយយើងឃើញពួកគេគឺមកទាន់ម៉ោង បានន័យថា
ពួកគេអត់មកយឺតជាងម៉ោងណាត់នោះទេ។ អញ្ចឹងពួកគេណាត់គ្នាម៉ោងប៉ុន្មាន
ពួកគេមកម៉ោងប៉ុននោះ អញ្ចឹងអត់មាននរណាម្នាក់យឺតនោះទេទោះបីជាស្ទះផ្លូវក៏ដោយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ជើងនារីម្នាក់នោះ ដោយសារតែស្ទះផ្លូវខ្លាំងពេក ហើយគាត់ខ្លាចមកខកការណាត់ ឬក៏ខ្លាចមកយឺត ដូច្នេះគាត់ក៏សម្រេចចិត្តរត់ និងជិះម៉ូតូឌុប ដើម្បីមកហាងកាហ្វេ ជួបនឹងមិត្តភក្តិរបស់គាត់ ដើម្បីកុំឲ្យយឺតម៉ោង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.